រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

*ថ្ងៃពុធ ៨រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៤២ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ១៦៦លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅកម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០២៦

ក្នុងខែកុម្ភៈ ឆ្នាំ២០២៦ គម្រោងវិនិយោគសរុបដែលត្រូវបានចុះបញ្ជីនៅកម្ពុជាទាំងការចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ទាំងការចុះបញ្ជីដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (អ.គ.វ.រ.ខ.) មានចំនួន ៤២ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ១៦៦លានដុល្លារអាម៉េរិក និងអាចបង្កើតការងារសរុបប្រមាណ ២៤ពាន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគទាំង៤២នេះ មានគម្រោងចំនួន ១៨ ត្រូវបានចុះបញ្ជីដោយ ក.អ.ក. (ក្រៅតំបន់សេដ្ឋកិច្ចពិសេសចំនួន ៩គម្រោង និងក្នុងតំបន់សេដ្ឋកិច្ចពិសេសចំនួន ៩គម្រោង) និងគម្រោងចំនួន ២៤ ត្រូវបានចុះបញ្ជីដោយ អ.គ.វ.រ.ខ.។ គម្រោងវិនិយោគ ដែលត្រូវបានចុះបញ្ជីក្នុងខែកុម្ភៈ ឆ្នាំ២០២៦នេះ មានជាអាទិ៍ គម្រោងវិនិយោគបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប, ផលិតកេសកាតុងនិងផលិតផលពីក្រដាស, ផលិតគ្រឿងសង្ហារិមសម្រាប់ប្រើប្រាស់ក្នុងផ្ទះ, ផលិតសម្ភារៈបោះជំរំ, កែច្នៃសំណប៉ាហាំង, ផលិតក្ដារបន្ទះ, ផលិតចំណៀរឈើ, កែច្នៃលោហធាតុ និងផលិតផលពីប្លាស្ទិក, ផលិតសារធាតុគីមី, ផលិតដើមណ្ដូអែល, ផលិតនិងផ្គុំដំឡើងក្បាលរ៉ូប៊ីណេ, ផលិតគ្រឿងបង្គុំបន្ទះសូឡានិងគ្រឿងបង្គុំបរិក្ខារអគ្គិសនី។ល។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគចាប់ពី ខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២៦

ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**គម្រោងវិនិយោគ**
**១០៥**
គម្រោង

**ទុនវិនិយោគ**
**៩៦៦** លាន
ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៣៩៣ពាន់**
កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)



**៣ លាន**
កសិកម្ម និងកសិ-ឧស្សាហកម្ម

**៤៦៤ លាន**
វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**៥០០ លាន**
វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៤៧,១៧% |
| ២. កម្ពុជា | ២២,១៦% |
| ៣. ម៉ាឡេស៊ី | ២០,៦៨% |
| ៤. សិង្ហបុរី | ៥,០៤% |
| ៥. កោះ British Virgin | ១,៧៦% |
| ៦. សហរដ្ឋអាម៉េរិក | ០,៨៣% |
| ៧. សីស្ហែល | ០,៧០% |
| ៨. កោះ Samoa | ០,៥៨% |
| ៩. សាធារណរដ្ឋកូរ៉េ | ០,៥៥% |
| ១០. ជប៉ុន | ០,៥៣% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត



ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែកុម្ភៈ ឆ្នាំ២០២៦

ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

| គម្រោងវិនិយោគ | ទុនវិនិយោគ | បង្កើតការងារ |
|---|---|---|
| **៤២** គម្រោង | **១៦៦** លាន ដុល្លារអាមេរិក | **~២៤ពាន់** កន្លែង |

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)



**១៦៦ លាន**
វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៨៥,២៨% |
| ២. កម្ពុជា | ៦,១០% |
| ៣. កោះ Samoa | ៣,៣៥% |
| ៤. សហរដ្ឋអាមេរិក | ៣,០១% |
| ៥. សិង្ហបុរី | ២,២៦% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត

